បោះពុម្ពឆ្នាំ2023



# ចំណងជើង៖
# សៀវភៅមគ្គុទ្ទេសក៍អំពីការរស់នៅខេត្តគីម៉ាម៉ុតុ
# សម្រាប់ជនបរទេស ពហុភាសា ភាសាខ្មែរ

日本語

English

中文(簡体字)

中文(繁体字)

한국어

Tiếng Việt

Tagalog

Indonesia

नेपाली

ភាសាខ្មែរ

မြန်မာစာ

**熊本県外国人サポートセンター**

(មជ្ឈមណ្ឌលគាំទ្រជនបរទេសខេត្តគីម៉ាម៉ុតុ)

# ផ្នែកក្រោយនៃក្របមុខ




វិបសាយទេសចរណ៍ខេត្តគីម៉ាម៉ុតុ

https://kumamoto.guide/

# មាតិកា


ណែនាំអំពីខេត្តគីម៉ាម៉ុត
ពេលមកដល់ប្រទេសជប៉ុន
- ↳កាតស្នាក់នៅ ........ 2
- ↳ចុះបញ្ជីស្នាក់នៅ........ 2
- ↳ការបង្កើតកាតម៉ាយណាំប័រ (លេខអត្តសញ្ញាណ)........ 3
- ↳ការចូលសោធននិវត្តន៍........ 4
- ↳ការចូលធានារ៉ាប់រងវេជ្ជសាស្ត្រជាតិ ........4
- ↳អំពីប្រាក់ពន្ធ ........ 5

ការរស់នៅ
- ↳ការជួបជុំក្នុងសហគម ........ 6
- ↳ប្រការប្រុងប្រយ័ត្នទាក់ទងការស្នាក់នៅ ........ 6
- ↳របៀបចោលសំរាម ........ 6

ចរាចរណ៍
- ↳កង់ ........ 8
- ↳រថយន្ត ........ 9
- ↳មធ្យោបាយធ្វើដំណើរសាធារណៈ ........10

ការធ្វើការ
- ↳គុណវុឌ្ឍិការងារ........11
- ↳ស្វែងរកការងារ ........11
- ↳កិច្ចសន្យាការងារ ........11
- ↳វិន័យមូលដ្ឋាន........12
- ↳លេខទូរសព្ទប្រឹក្សាពិគ្រោះសម្រាប់ពលករបរទេស ........13
- ↳ប្រព័ន្ធធានារ៉ាប់រងសាធារណៈ ...13

ជំងឺនិងរបួស
- ↳អំពីធានារ៉ាប់រងវេជ្ជសាស្ត្រ ........14
- ↳អំពីគ្រូពេទ្យគ្រួសារ ........15
- ↳សៀវភៅកត់ត្រាថ្នាំពេទ្យ........15
- ↳ប្រព័ន្ធចំណាយថ្លៃព្យាបាលខ្ពស់ ...15

មានផ្ទៃពោះនិងសម្រាលកូន
- ↳ពេលមានផ្ទៃពោះ ........16
- ↳ការពិនិត្យផ្ទៃពោះ ........16
- ↳បែបបទក្រោយសម្រាលកូន ........16
- ↳ការពិនិត្យសុខភាព និងចាក់វ៉ាក់សាំងជាប្រចាំ ........17
- ↳ប្រាក់ឧបត្ថម្ភ ........17
- ↳ឧបត្ថម្ភដល់ឪពុកឬម្ដាយតែម្នាក់ ...18
- ↳កន្លែងប្រឹក្សាពិគ្រោះ........18

ការអប់រំកុមារ
- ↳មណ្ឌលសុខភាពនិងសាលាមត្តេយ្យ........ 19
- ↳ទារកដ្ឋានដែលមានការបញ្ជាក់...19
- ↳សាលាមត្តេយ្យ ........19
- ↳ការអប់រំនៅសាលា ........20
- ↳សាលាអន្តរជាតិ........21
- ↳អនុវិទ្យាល័យពេលយប់ ........21

ត្រៀមសម្រាប់គ្រោះមហន្តរាយ
- ↳រញ្ជួយដី........22
- ↳ខ្យល់ព្យុះ ........23
- ↳ពេលគ្រោះមហន្តរាយ ........24

ពេលអាសន្ន
- ↳គ្រោះថ្នាក់SOS ........25
- ↳ប៉ូលីស (ឧប្បត្តិហេតុ) ........25

ប្រឹក្សាពិគ្រោះ
- ↳មជ្ឈមណ្ឌលគាំទ្រជនបរទេសខេត្តគីម៉ាម៉ុត........26

# ពេលមកដល់ប្រទេសជប៉ុន

☑ សូមពិនិត្យដោយគូស

## ☐ យកកាតស្នាក់នៅតាមខ្លួនជានិច្ច

វាត្រូវបានផ្តល់ឱ្យ នៅពេលអ្នកស្នាក់នៅប្រទេសជប៉ុនចាប់ពី3ខែឡើង។

【ផ្នែកមុខ】




【ផ្នែកខ្នង】




ប្រសិនបើអ្នកមានបញ្ហាណាមួយទាក់ទងនឹងការស្នាក់នៅរបស់អ្នក ដូចជាការពន្យាររយៈពេលស្នាក់នៅ ការផ្លាស់ប្តូរស្ថានភាពស្នាក់នៅ បាត់កាត ហើយចង់ចេញកាតនេះជាថ្មី ឬត្រឡប់ទៅប្រទេសកំណើតជាបណ្តោះអាសន្ន សូមបំពេញបែបបទនៅនាយកដ្ឋានអន្តោប្រវេសន៍។

🔍 នាយកដ្ឋានអន្តោប្រវេសន៍ហ្វ៊ីគីអុកា ការិយាល័យគឹម៉ាម៉ុតុ ទូរសព្ទ៖ 096-362-1721

## ☐ ចុះបញ្ជីស្នាក់នៅ នៅសាលាភូមិសង្កាត់ខណ្ឌក្រុង

ប្រសិនបើរស់នៅប្រទេសជប៉ុនលើសពី3ខែ អ្នកចាំបាច់ចុះបញ្ជីស្នាក់នៅតាមរយៈ"ប័ណ្ណស្នាក់នៅ"។

ត្រូវដាក់សេចក្តីជូនដំណឹងពីអាសយដ្ឋានរបស់អ្នកនៅច្រកភូមិសង្កាត់ខណ្ឌក្រុង។ សូមបំពេញបែបបទក្នុងរយៈពេល14ថ្ងៃ។

វាចាំបាច់នៅពេលអ្នកទទួលសេវារដ្ឋបាល។

【ការផ្លាស់ប្តូរទីលំនៅ】

① មុនផ្លាស់ប្តូរទីលំនៅ សូមបំពេញបែបបទ "ជូនដំណឹងផ្លាស់ចេញ" នៅច្រក

ភូមិសង្កាត់ក្រុងបច្ចុប្បន្ន។
② "លិខិតបញ្ជាក់ផ្លាស់ចេញ" នឹងត្រូវបានផ្តល់ជូន។
③ ក្រោយផ្លាស់ប្តូរទីលំនៅ សូមបំពេញបែបបទ "ជូនដំណឹងផ្លាស់ចូល" នៅច្រក ភូមិសង្កាត់ក្រុងថ្មីដែលបានផ្លាស់មក។ សូមបំពេញបែបបទក្នុងរយៈពេល14ថ្ងៃ។ ដោយយកទៅនូវ កាតស្នាក់នៅ លិខិតបញ្ជាក់ផ្លាស់ចេញ កាតម៉ាយណាំប័រ។

* បែបបទគឺពុំគិតថ្លៃទេ។
* ប្រសិនបើលើលិខិតឆ្លងដែនរបស់អ្នកសរសេរថា "កាតស្នាក់នៅនឹងត្រូវបាន ចេញនៅពេលក្រោយ" សូមយកលិខិតឆ្លងដែនរបស់អ្នកទៅបំពេញបែបបទ។ កាតស្នាក់នៅរបស់អ្នកនឹងត្រូវបានផ្ញើទៅអាសយដ្ឋានដែលអ្នកបានជូនដំណឹង នៅពេលក្រោយ។
* បែបបទផ្លាស់ប្តូរអាសយដ្ឋាននៅលើប័ណ្ណបើកបររបស់អ្នក ត្រូវបំពេញនៅ មជ្ឈមណ្ឌលប័ណ្ណបើកបរ។
* ប្រសិនបើអ្នកទៅក្រៅប្រទេស ឬត្រឡប់ទៅប្រទេសកំណើតរបស់អ្នកលើស ពី1ឆ្នាំ អ្នកត្រូវបំពេញបែបបទ "ជូនដំណឹងផ្លាស់ចេញ"។

## ☑ ការបង្កើតកាតម៉ាយណាំប័រ (លេខអត្តសញ្ញាណ)

ជាកាតមានលេខ12ខ្ទង់ដែលផ្តល់ឱ្យអ្នកគ្រប់គ្នាដែលមានប័ណ្ណស្នាក់នៅ។
នៅពេលអ្នកដាក់ពាក្យសុំ អ្នកអាចប្រើវាជា"ប័ណ្ណធានារ៉ាប់រងសុខភាព (ប័ណ្ណធានារ៉ាប់រងក្នុងករណីមានជំងឺឬរបួស)"។
វាចាំបាច់នៅពេល ផ្ញើប្រាក់ទៅក្រៅប្រទេស, ធ្វើការនៅក្រុមហ៊ុន (បែបបទ បើកប្រាក់ខែ) និងទទួលសេវារដ្ឋបាល។
កុំប្រាប់លេខរបស់អ្នកទៅនរណាម្នាក់ លុះត្រាពេលចាំបាច់សម្រាប់បែបបទ។





ឯកសារដាក់ពាក្យនឹងត្រូវបានផ្ញើទៅអ្នក ពីភូមិសង្កាត់ខណ្ឌក្រុងដែលអ្នកកំពុង រស់នៅ។
សូមបំពេញប្រការចាំបាច់ក្នុងពាក្យសុំ ហើយដាក់ពាក្យសុំបង្កើតកាត តាម ប្រៃសណីយ៍ ឬស្មាតហ្វូន។

អំពីកាតម៉ាយណាំប័រ
https://www.kojinbango-card.go.jp/

## ការចូលធានារ៉ាប់រងវេជ្ជសាស្ត្រជាតិ

ការធានារ៉ាប់រងវេជ្ជសាស្ត្រសាធារណៈរបស់ប្រទេសជប៉ុនគឺចាំបាច់សម្រាប់មនុស្សគ្រប់រូបដើម្បីទទួលបានសេវាវេជ្ជសាស្ត្រស្មើៗគ្នា។
ថ្លៃធានារ៉ាប់រងដែលអ្នកបង់នឹងប្រែប្រួលអាស្រ័យលើប្រាក់ចំណូលរបស់អ្នកប្រចាំឆ្នាំមុន។

"ប្រាក់កញ្ចប់សម្រាលកូន" នឹងត្រូវបានបង់ជាថ្លៃធានារ៉ាប់រងនៅពេលអ្នកសម្រាលកូន អាស្រ័យតាមលក្ខខណ្ឌ។
លម្អិតសូមអាន < ជំងឺនិងរបួស > P.14

## ការចូលសោធននិវត្តន៍

វាចាំបាច់សម្រាប់ជីវិតប្រចាំថ្ងៃរបស់អ្នក នៅពេលអ្នកក្លាយជាជនពិការដោយសាររបួស ឬជំងឺ ឬនៅពេលដែលអ្នកមិនអាចធ្វើការបានដោយសារអាយុចាស់។
មនុស្សទាំងអស់ដែលរស់នៅក្នុងប្រទេសជប៉ុន (អាយុពី20ទៅ59ឆ្នាំ) មានកាតព្វកិច្ចចូលសោធននិវត្តន៍។

| ប្រភេទ | សម្រាប់អ្នក (អាយុចាប់ពី20 ដល់ក្រោម60ឆ្នាំ) | ទឹកប្រាក់ត្រូវបង់ |
|---|---|---|
| សោធននិវត្តន៍ជាតិ | អ្នកមានមុខរបរផ្ទាល់ខ្លួន<br>អ្នកមិនធ្វើការ និងនិស្សិតបរទេស | ទៅតាមចំនួនសមាជិកនិងចំណូលគ្រួសារ។<br>ប័ណ្ណទូទាត់នឹងត្រូវផ្ញើទៅអ្នក។ |
| សោធននិវត្តន៍សុខុមាលភាព | អ្នកធ្វើការនៅក្រុមហ៊ុន | ទៅតាមប្រាក់ចំណូល។<br>ក្រុមហ៊ុនបង់មួយផ្នែក។ |

* ចំពោះសិស្សនិស្សិត ឬប្រាក់ចំណូលទាបជាងស្តង់ដារ អ្នកអាចត្រូវបានលើកលែង ឬផ្តល់ការពន្យាពេលបង់ថ្លៃធានារ៉ាប់រង។ សូមប្រឹក្សាពិគ្រោះនៅច្រក "សោធននិវត្តន៍ជាតិ" នៃភូមិសង្កាត់ក្រុង។
* ជនបរទេសដែលបានបង់ប្រាក់សោធននិវត្តន៍លើសពី6ខែ អាចទទួលបានចំណែកនៃថ្លៃធានារ៉ាប់រងរបស់ពួកគេវិញ អាស្រ័យលើលក្ខខណ្ឌ ប្រសិនបើពួកគេបំពេញបែបបទ "ប្រាក់កញ្ចប់ដកចេញ" បន្ទាប់ពីត្រឡប់ទៅប្រទេសកំណើតរបស់ខ្លួន។

គេហទំព័រសេវាកម្មសោធននិវត្តន៍ជប៉ុន
https://www.nenkin.go.jp/international/index.html

## សូមបង់ពន្ធឱ្យបានត្រឹមត្រូវ

### ប្រភេទនៃពន្ធ

| | |
|---|---|
| ពន្ធស្នាក់នៅ | វាត្រូវបានគណនាដោយផ្អែកលើប្រាក់ចំណូលឆ្នាំមុន និងត្រូវបង់ក្នុងឆ្នាំបន្ទាប់។ វាត្រូវបានប្រើប្រាស់ដោយខេត្តនិងភូមសង្កាត់ខណ្ឌក្រុង ដើម្បីផ្តល់ការចំណាយសម្រាប់សេវាកម្មចាំបាច់សម្រាប់ជីវិតប្រចាំថ្ងៃរបស់អ្នករស់នៅ (ការអប់រំ សុខុមាលភាព ជំនួយបឋម ការចោលសំរាម) ។ |
| ពន្ធប្រាក់ចំណូល | បង់តាមចំណូល (ប្រាក់ខែ) នៃឆ្នាំនោះ។ |
| ពន្ធប្រើប្រាស់ | វាត្រូវបានគិត រាល់ពេលដែលអ្នកទិញផលិតផល ឬសេវាកម្ម។ មានសរសេរលើរស៊ីត។ |
| ក្រៅពីនេះ ក៏មានពន្ធរថយន្តដែលបង់ជារៀងរាល់ឆ្នាំ តាមប្រភេទរថយន្ត ឬម៉ូតូដែលអ្នកប្រើ។ | |

* ពន្ធស្នាក់នៅ និងពន្ធប្រាក់ចំណូលអាចនឹងត្រូវបានលើកលែង ប្រសិនបើដាក់ពាក្យសុំដោយផ្អែកលើសន្ធិសញ្ញាពន្ធរវាងប្រទេសកំណើតរបស់អ្នក និងប្រទេសជប៉ុន។

### អ្វីជាការប្រកាសពន្ធ?

គណនាប្រាក់ចំណូលទាំងអស់ដែលរកបានចាប់ពីថ្ងៃ1ខែមករា ដល់ ថ្ងៃ31ខែធ្នូ រួចរាយការណ៍ទៅរដ្ឋាភិបាលជារៀងរាល់ឆ្នាំ ហើយបង់ពន្ធ។
អាចបំពេញបែបបទតាមមួយណាក៏បាន ①យកឯកសារទៅការិយាល័យពន្ធដារ, ②ផ្ញើតាមប្រៃសណីយ៍, ③អ៊ីនធឺណិត។
ប្រសិនបើអ្នកកំពុងទទួលបានប្រាក់បៀវត្សរ៍ ក្រុមហ៊ុនដែលអ្នកធ្វើការឱ្យនឹងធ្វើការកែតម្រូវចុងឆ្នាំ (គណនាពន្ធប្រាក់ចំណូល និងគណនាកាត់ប្រាក់ទូទាត់) ។

### វិញ្ញាបនបត្របង់ពន្ធ

ឯកសារខាងក្រោមអាចត្រូវបានទាមទារនៅពេលទទួលបានសេវាស្នាក់នៅ (ប្រាក់ឧបត្ថម្ភកុមារ។ល។) ។
វិញ្ញាបនបត្របង់ពន្ធ (ការបញ្ជាក់ការបង់ពន្ធ)៖ អាចរកបាននៅការិយាល័យផ្សព្វផ្សាយតំបន់ ឬសាលាខេត្ត។
វិញ្ញាបនបត្រជាប់ពន្ធ (ការបញ្ជាក់ទឹកប្រាក់ពន្ធស្នាក់នៅដែលជាប់ តាមប្រាក់ចំណូលឆ្នាំមុន)៖ អាចរកបានវានៅសាលាភូមិសង្កាត់ក្រុងដែលអ្នករស់នៅ។

ព័ត៌មានលម្អិត

🔍 ទីភ្នាក់ងារជាតិពន្ធដារ

https://www.nta.go.jp/ (ភាសាជប៉ុន)

https://www.nta.go.jp/english/index.htm (ភាសាអង់គ្លេស)

(ភាសាជប៉ុន)

(ភាសាអង់គ្លេស)

# ការរស់នៅ



## ការជួបជុំក្នុងសហគម

មានការប្រមូលផ្តុំនៅក្នុងសហគមដែលអ្នករស់នៅ ដូចជាការចូលរួមក្នុងសកម្មភាពសម្អាត ការរៀបចំព្រឹត្តិការណ៍ និងការបង់ថ្លៃសមាជិកភាពសង្កាត់។ ឬហៅថា "សមាគមអ្នកស្រុក / សមាគមក្នុងសង្កាត់" ។
អ្នកអាចបង្កើតទំនាក់ទំនងទល់មុខគ្នានៅក្នុងតំបន់ដែលអ្នករស់នៅ ដូច្នេះសូមចូលរួមយ៉ាងសកម្មក្នុងសកម្មភាពសហគម។
ប្រសិនបើអ្នកមិនយល់អ្វីមួយ សូមសួរ "ប្រធានសមាគម" ។

## នៅពេលជួលផ្ទះ សូមគោរពតាម"កិច្ចសន្យា"។

នៅពេលជួលផ្ទះ អ្នកប្រហែលជាត្រូវបង់ថ្លៃប្រាក់កក់ ប្រាក់អំណរគុណ អ្នកធានា និងថ្លៃសម្អាតបន្ទប់ នៅពេលអ្នកចាកចេញ។
កុំបញ្ចេញសំឡេងខ្លាំងៗជាមួយមិត្តភ័ក្តិ នៅពេលយប់ជ្រៅក្នុងបន្ទប់ផ្ទះល្វែងរបស់អ្នក (លំនៅឋានប្រមូលផ្តុំ)។
សូមកុំទុករបស់របរនៅតាមផ្លូវ ឬតាមជណ្តើរ។
កុំជួលបន្ទប់របស់អ្នកឱ្យអ្នកផ្សេង។
អ្នកនឹងធ្វើកិច្ចសន្យាសម្រាប់អគ្គិសនី ហ្គាស ទឹក និងអ៊ីនធឺណិតដោយខ្លួនឯង។
អ្នកនឹងលុបចោលកិច្ចសន្យាដោយខ្លួនឯងនៅពេលអ្នកចាកចេញ។
កង់ ម៉ូតូ និងរថយន្តត្រូវតែចាក់សោ និងចតនៅកន្លែងដែលបានកំណត់។

## ចោលសំរាមតាមពេលវេលាជាក់លាក់ និងទីតាំងជាក់លាក់។

"ប្រតិទិនសំរាម" មានកាលវិភាគនៃពេលវេលា និងសំរាមប្រភេទណាដែលត្រូវប្រមូល។
អ្នកអាចទទួលបានវាដោយឥតគិតថ្លៃនៅច្រកនៃការិយាល័យរដ្ឋាភិបាល។

ដើម្បីកែច្នៃឡើងវិញ ចាំបាច់ត្រូវបែងចែកប្រភេទសំរាម។ សូមអនុវត្តតាមវិធីបំបែករបស់ភូមិសង្កាត់ក្រុងដែលអ្នករស់នៅ។

ឧទាហរណ៍)

សំរាមដុតឆេះ



ក្រដាស,



សំរាមអាចកែច្នៃ



ប្លាស្ទិក



ដបប្លាស្ទិក



ប្រភេទជាក់លាក់
កំប៉ុងស្រ្គាយ ដែកកេះ អាគុយស្ងួត។ល។




* អ្នកក៏អាចប្រើថង់សំរាមដែលគិតថ្លៃផងដែរ។
* កុំបង្ហូរប្រេងដែលប្រើសម្រាប់ចម្អិនអាហារចូលក្នុងផ្ទះបាយ។ ផ្ចិតជក់វាជាមួយនឹងក្រដាសកាសែត ឬក្រដាសធម្មតា ឬដាក់ជាប់ម្សៅ ហើយចោលក្នុងសំរាមដុតឆេះ។
* របស់ដែលមិនអាចដាក់ក្នុងថង់សំរាម ត្រូវបានគេចាត់ទុកថាជា"សំរាមធំ"។ នៅពេលចោលសំរាម ត្រូវយកវាទៅកន្លែងចោលសំរាមដោយខ្លួនឯង (គិតថ្លៃសេវាអាស្រ័យលើប្រភេទសំរាម) ឬទូរស័ព្ទទៅលេខដែលមានដាក់លើគេហទំព័ររបស់ភូមិសង្កាត់ក្រុងដែលអ្នករស់នៅ។ ទិញ "ស្ទីគ័រប្រមូលសំរាមធំ" នៅហាងងាយស្រួល បិទស្ទីគ័រនៅកន្លែងដែលបានកំណត់ ហើយចោលវា។
* នៅពេលបោះចោលរបស់របរដូចជា ម៉ាស៊ីនបោកគក់ ទូទឹកកក និងទូរទស្សន៍ សូមពឹងពាក់សេវាប្រមូល។ (គិតថ្លៃ)

# ចរាចរណ៍



## វិន័យពេលជិះកង់

① បររត់ខាងឆ្វេងនៃផ្លូវឡាន



② នៅផ្លូវបំបែកប្រសព្វ ត្រូវគោរពភ្លើងសញ្ញាចរាចរណ៍ ហើយឈប់សិន។



③ បើកភ្លើងបំភ្លឺនៅពេលយប់



④ មិនត្រូវបើកបរពេលផឹកជាតិអាល់កុល




⑤ ពាក់មួកសុវត្ថិភាព



· មិនត្រូវជិះ2នាក់
· ការបើកបរដោយប្រើឆ័ត្រ ឬប្រើប្រាស់ស្មាតហ្វូនត្រូវបានហាមឃាត់
· ចតនៅក្នុងចំណតដែលបានកំណត់
ចំណតកង់នៅកណ្តាលទីក្រុងគឺម៉ាម៉ុតុ ទាមទារថ្លៃចំណត។
· មិនត្រូវទុកចោល
· ត្រូវចូលធានារ៉ាប់រងកង់ (ជាការកំណត់របស់ខេត្តគឺម៉ាម៉ុតុ)
ជាធានារ៉ាប់រងក្នុងករណីដែលអ្នកជួបគ្រោះថ្នាក់ដោយសារកង់។
· ចុះបញ្ជីបង្ការឧក្រិដ្ឋកម្ម (ថ្លៃចុះបញ្ជី 660យ៉េន) ។
ចុះបញ្ជីកង់នៅហាងលក់កង់ ដើម្បីបញ្ជាក់ថាវាជារបស់អ្នក។

* សេវាកម្មជួលកង់បង់ថ្លៃក៏មាននៅទូទាំងខេត្តផងដែរ។

## ប័ណ្ណបើកបររថយន្ត

ដើម្បីបើកបរនៅប្រទេសជប៉ុន អ្នកចាំបាច់មានប័ណ្ណបើកបរមួយក្នុងចំណោមខាងក្រោម។
① ប័ណ្ណបើកបរនៃប្រទេសជប៉ុន
② ប័ណ្ណបើកបរអន្តរជាតិ
③ ប័ណ្ណបើកបរនៃប្រទេសឬតំបន់ដែលកំណត់

ចំពោះអ្នកមានប័ណ្ណបើកបរបរទេស សូមទៅមជ្ឈមណ្ឌលប័ណ្ណបើកបរដើម្បីប្តូរជាប័ណ្ណដែលអាចប្រើបាននៅក្នុងប្រទេសជប៉ុន។
តម្រូវឱ្យកក់ទុកជាមុន។
ទំនាក់ទំនង៖ ទីស្នាក់ការកណ្តាលនគរបាលខេត្តគឺម៉ាម៉ុតុ ផ្នែកប្រឡងយកប័ណ្ណបើកបរ 096-233-0116

## អ្នកយកប័ណ្ណបើកបរ

មានការប្រឡងសរសេរជាភាសាបរទេស (ចិន អង់គ្លេស វៀតណាម)។ (គិតត្រឹមខែកក្កដា ឆ្នាំ2022)

## មធ្យោបាយធ្វើដំណើរសាធារណៈ

ការប្រើប្រាស់ICកាត និងអេបជិះប្តូរ ពេលជិះរថភ្លើងនិងឡានក្រុង មានភាពងាយស្រួល។

វិន័យពេលជិះរថភ្លើង និងឡានក្រុងនៅប្រទេសជប៉ុន

· មុនចូលជិះ ត្រូវតម្រង់ជួរតាមលេខរៀង ចាំនៅកន្លែងដែលបានកំណត់
· កំណត់ទូរសព្ទ័របស់អ្នកទៅជាម៉ូដស្ងាត់ ហើយមិននិយាយទូរសព្ទនៅខាងក្នុងរថយន្ត។
· មិននិយាយដោយសំឡេងខ្លាំងៗ
· មិនបរិភោគក្នុងរថយន្ត
· មិនចោលសំរាមនៅស្ថានីយ ចំណតរថយន្តក្រុង និងក្នុងរថយន្ត

# ការធ្វើការ

## ចំពោះការធ្វើការនៅប្រទេសជប៉ុន អ្នកត្រូវធ្វើការងារដែលត្រូវនឹងស្ថានភាពស្នាក់នៅរបស់អ្នក។

ការធ្វើការដែលផ្ទុយនឹងស្ថានភាពស្នាក់នៅរបស់អ្នក ត្រូវបានហាមឃាត់ដោយច្បាប់។

ទោះបីជាអ្នកមានស្ថានភាពដែលមិនអនុញ្ញាតឱ្យធ្វើការក៏ដោយ ក៏អ្នកអាចទទួលបាន"ការអនុញ្ញាតឱ្យចូលរួមសកម្មភាពផ្សេងក្រៅពីស្ថានភាពស្នាក់នៅ" ដែលផ្តល់ដោយទីភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍។ មានដែនកំណត់ចំពោះចំនួនម៉ោងដែលអ្នកអាចធ្វើការបាន។

## ពេលស្វែងរកការងារ សូមចុះឈ្មោះនៅ "ហេឡូវើក"

"ហេឡូវើក (ការិយាល័យសន្តិសុខការងារ)" គឺជាស្ថាប័នជាតិដែលអនុញ្ញាតឱ្យអ្នកបំពេញបែបបទស្វែងរកការងារ និងបែបបទធានារ៉ាប់រងការងារដោយមិនគិតថ្លៃ។

នៅពេលផ្លាស់ប្តូរការងារ សូមបញ្ជាក់ជាមួយនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីមើលថាតើអ្នកអាចធ្វើការងារថ្មីជាមួយនឹងស្ថានភាពស្នាក់នៅបច្ចុប្បន្នរបស់អ្នកដែរឬទេ។
វាអាចជាការប្រសើរក្នុងការដាក់ពាក្យសុំ "វិញ្ញាបនបត្រអនុញ្ញាតធ្វើការ"។
សូមដាក់ "ការជូនដំណឹងទាក់ទងនឹងអង្គភាពចុះកិច្ចសន្យា (ការបង្កើតកិច្ចសន្យាថ្មី)" ទៅនាយកដ្ឋានអន្តោប្រវេសន៍ ក្នុងរយៈពេល14ថ្ងៃបន្ទាប់ពីផ្លាស់ប្តូរការងារ។

## សូមពិនិត្យ"កិច្ចសន្យា"ពេលចាប់ផ្តើមការងារ។

នៅពេលសម្រេចជាប់ការងារ ត្រូវចងភ្ជាប់កិច្ចសន្យាជាមួយក្រុមហ៊ុនដែលអ្នកនឹងធ្វើការ។
ឈ្មោះឯកសារគឺ "កិច្ចសន្យាការងារនិងពលកម្ម" ឬ "សេចក្តីជូនដំណឹងអំពីលក្ខខណ្ឌពលកម្ម"។

ត្រូវពិនិត្យមើលថាតើមានសរសេរអំពីខ្លឹមសារការងារ ចំនួនថ្ងៃធ្វើការ ថ្ងៃឈប់សម្រាកនិងច្បាប់ឈប់សម្រាក និងប្រាក់ខែ(ប្រាក់ឈ្នួល) ដែរឬទេ។
ត្រូវប្រាកដថាអ្នកយល់ និងយល់ព្រមចំពោះខ្លឹមសារ រួចហើយចុះហត្ថលេខា។

ច្បាប់កំណត់ប្រាក់ឈ្នួលម៉ោងអប្បបរមា ហើយប្រាក់ឈ្នួលម៉ោងត្រូវតែស្មើនឹងឬខ្ពស់ជាង "ប្រាក់ឈ្នួលអប្បបរមា"។
"ប្រាក់ឈ្នួលអប្បបរមា" ប្រែប្រួលអាស្រ័យលើខេត្តក្រុង និងការងារ។

ចង់ដឹងបន្ថែម
ស្វែងរកលើអ៊ីនធឺណិត "ខេត្តគីម៉ាម៉ុតុ ប្រាក់ឈ្នួលអប្បបរមា"

## ប្រការកំណត់ជាមូលដ្ឋាន សម្រាប់អ្នកធ្វើការនៅប្រទេសជប៉ុន

- ជាគោល, ម៉ោងធ្វើការត្រូវបានកំណត់។
  អ្នកអាចធ្វើការ8ម៉ោងចុះក្នុងមួយថ្ងៃ ហើយមិនអាចធ្វើការលើស40ម៉ោងក្នុងមួយសប្តាហ៍ឡើយ។
- ម៉ោងសម្រាកចាំបាច់ក្នុង1ថ្ងៃ
  ចាប់ពី45នាទី (នៅពេលធ្វើការចាប់ពី6ម៉ោង), ចាប់ពី1ម៉ោង (នៅពេលធ្វើការចាប់ពី8ម៉ោង)
- ថ្ងៃឈប់សម្រាក
  4ថ្ងៃឡើងក្នុង4សប្តាហ៍
- ប្រាក់ឈ្នួលបន្ថែមនឹងត្រូវបានទូទាត់សម្រាប់ការងារបន្ថែមម៉ោង (អាស្រ័យលើប្រភេទការងារ និងស្ថានភាពស្នាក់នៅ)។
- នៅពេលដែលក្រុមហ៊ុនបញ្ឈប់បុគ្គលិក ចាំបាច់មានការជូនដំណឹងជាមុន30ថ្ងៃ។ ប្រសិនបើក្រុមហ៊ុនមិនបានធ្វើដូច្នេះទេ ក្រុមហ៊ុនត្រូវទូទាត់ជូននិយោជិតនូវប្រាក់បំណាច់ចំពោះការជូនដំណឹងអំពីការបញ្ឈប់ការងារ។
- ការឈប់សម្រាកដែលមានប្រាក់ឈ្នួលនឹងត្រូវបានផ្តល់រយៈពេល10ថ្ងៃ ប្រសិនបើនិយោជិតបានធ្វើការលើសពី6ខែ ហើយអត្រាវត្តមានមកធ្វើការគឺចាប់ពី80%។
  មួយឆ្នាំក្រោយមក ចាប់ពី11ថ្ងៃនឹងត្រូវបានផ្តល់ឱ្យ។
  ការឈប់សម្រាកដែលមានប្រាក់ឈ្នួល អាចអនុវត្តទៅឆ្នាំបន្ទាប់ ប៉ុន្តែនឹងផុតកំណត់បន្ទាប់ពី2ឆ្នាំ។

* ត្រូវគ្រប់គ្រងបង្កាន់ដៃប្រាក់ខែ (លម្អិតនៃប្រាក់ខែ) ដោយផ្ទាល់ខ្លួន។

* ត្រូវកត់ត្រាការគ្រប់គ្រងវត្តការងារឱ្យបានត្រឹមត្រូវ (ម៉ោងចាប់ផ្តើមការងារ និង ម៉ោងប៉ុន្មានដែលអ្នកបានបញ្ចប់ការងារ) ។
* ត្រូវគ្រប់គ្រងលិខិតឆ្លងដែន និងកាតស្នាក់នៅដោយផ្ទាល់ខ្លួន។ កុំទុកវាជាមួយក្រុមហ៊ុនក្នុងរយៈពេលយូរ។

## លេខទូរសព្ទប្រឹក្សាពិគ្រោះសម្រាប់ពលករបរទេស

ងប្រទេសជប៉ុន មានច្បាប់ការពារអ្នកកំពុងធ្វើការ។
ប្រសិនបើអ្នកកំពុងជួបប្រទះការប្រព្រឹត្តិដោយអយុត្តិធម៌ពីក្រុមហ៊ុនដែលអ្នកធ្វើការ (ត្រូវបានបង្ខំឱ្យឈប់ពីការងារ កាត់បន្ថយប្រាក់ឈ្នួល ការធ្វើបាបឬការបៀតបៀនដោយអំណាច។ល។) ឬមានបញ្ហា អ្នកអាចប្រឹក្សាពិគ្រោះតាមទូរស័ព្ទដោយឥតគិតថ្លៃ។
(អស់ថ្លៃទូរសព្ទ)
https://www.startup-roudou.mhlw.go.jp/foreigner.html

## ប្រព័ន្ធធានារ៉ាប់រងសាធារណៈ នៅពេលអ្នកមិនអាចធ្វើការបានទៀតទេ

| ប្រភេទ | ខ្លឹមសារ (មានលក្ខខណ្ឌក្នុងការផ្តល់ឱ្យ) |
|---|---|
| ប្រាក់ឧបត្ថម្ភគោល (ឧបត្ថម្ភបាត់បង់ការងារ) | បន្ទាប់ពីអ្នកចូលនិវត្តន៍ អ្នកនឹងទទួលបានអត្ថប្រយោជន៍ក្នុងរយៈពេលជាក់លាក់មួយ រហូតដល់អ្នកចាប់ផ្តើមការងារថ្មី។ |
| ប្រាក់ឧបត្ថម្ភឈប់សម្រាកមើលថែកូន | អត្ថប្រយោជន៍ត្រូវបានផ្តល់ជូននៅពេលសម្រាកយូរពីការងារដើម្បីមើលថែកូន។ |
| ប្រាក់ឧបត្ថម្ភឈប់សម្រាកថែទាំ | អត្ថប្រយោជន៍ត្រូវបានផ្តល់ជូននៅពេលសម្រាកយូរពីការងារ ដើម្បីថែទាំសមាជិកគ្រួសារ។ |
| ប្រាក់ឧបត្ថម្ភរបួសជំងឺ | ត្រូវបានផ្តល់ជូន នៅពេលអ្នកអវត្តមានពីក្រុមហ៊ុនដោយសារជំងឺឬរបួស។ |

# ជំងឺ របួស

អ្នកទាំងអស់ដែលរស់នៅក្នុងប្រទេសជប៉ុនអាចចូលធានារ៉ាប់រងវេជ្ជសាស្ត្រសាធារណៈ និងទទួលបានសេវាវេជ្ជសាស្ត្រ។
នៅពេលអ្នកមានជំងឺ ជាដំបូងទៅមន្ទីរពេទ្យក្បែរនោះ។

**មាន២ប្រភេទនៃធានារ៉ាប់រងវេជ្ជសាស្ត្រសាធារណៈ ដែលចាំបាច់ក្នុងការពិនិត្យនៅមន្ទីរពេទ្យ។**

| | ធានារ៉ាប់រងសុខភាពជាតិ | ធានារ៉ាប់រងសង្គម |
|---|---|---|
| ខ្លឹមសារ | 30%នៃថ្លៃព្យាបាលគឺជាបន្ទុកសមីខ្លួន។ | |
| សម្រាប់អ្នក | អ្នកមិនធ្វើការ ឬមានមុខរបរផ្ទាល់ខ្លួន | អ្នកធ្វើការនៅក្រុមហ៊ុន |
| ថ្លៃធានារ៉ាប់រង | កំណត់តាមប្រាក់ចំណូល | |
| ប្រាក់កញ្ចប់សម្រាលកូន | មាន | |
| ប្រាក់ឧបត្ថម្ភសម្រាលកូន ប្រាក់ឧបត្ថម្ភរបួសជំងឺ | គ្មាន | មាន |
| ទំនាក់ទំនង | ផ្នែកធានារ៉ាប់រងសុខភាពជាតិ នៃភូមិសង្កាត់ខណ្ឌក្រុង | សមាគមធានារ៉ាប់រងសុខភាពជាតិ |

* អ្នកមកពីប្រទេសដែលមានកិច្ចព្រមព្រៀងសន្តិសុខសង្គមជាមួយប្រទេសជប៉ុន អាចមិនចាំបាច់ចូលទេ។
* បុគ្គលិកក្រៅម៉ោងឬផាតថាម អាចចូលធានារ៉ាប់រងសុខភាពជាតិ ជំនួសធានារ៉ាប់រងសង្គម។

## អំពីគ្រូពេទ្យគ្រួសារ

ជាស្ថាប័នវេជ្ជសាស្ត្រដែលមានទីតាំងនៅជិតផ្ទះ ដែលអ្នកអាចប្រឹក្សាពិគ្រោះអំពីស្ថានភាពសុខភាពប្រចាំថ្ងៃ។
ជាពិសេសសម្រាប់អ្នកដែលមានជំងឺរ៉ាំរ៉ៃក្នុងការសម្រេចយកគ្រូពេទ្យគ្រួសារ។
មន្ទីរពេទ្យធំៗដូចជាមន្ទីរពេទ្យសាកលវិទ្យាល័យមានផ្នែកជំនាញពិនិត្យច្រើន ប៉ុន្តែអ្នកប្រហែលជាមិនអាចទទួលការពិនិត្យ ដោយគ្មានលិខិតណែនាំ ហើយថ្លៃសេវាអាចនឹងខ្ពស់។
ដំបូងគឺត្រូវប្រឹក្សាពិគ្រោះជាមួយគ្រូពេទ្យគ្រួសារ ហើយជាធម្មតាឱ្យគាត់សរសេរលិខិតណែនាំ។

## ការពិនិត្យនៅស្ថាប័នវេជ្ជសាស្ត្រ

- អាស្រ័យលើមន្ទីរពេទ្យថាតើអាចធ្វើការណាត់ជួបដើម្បីពិនិត្យលើកដំបូងបានឬទេ។ ត្រូវទាក់ទងតាមទូរសព្ទ។
- ពេលទទួលការពិនិត្យនៅមន្ទីរពេទ្យ គឺត្រូវដាក់ប័ណ្ណធានារ៉ាប់រងសុខភាពរបស់ខ្លួន ឬកាតម៉ាយណាំប័រ។
- ប្រសិនបើមានការធ្វើតេស្ត អ្នកនឹងត្រូវចុះហត្ថលេខាលើទម្រង់យល់ព្រម។ ប្រសិនបើគ្មានទំនុកចិត្តលើភាសាជប៉ុនរបស់អ្នកទេ សូមទៅជាមួយអ្នកដែលយល់ភាសាជប៉ុន។
- ការពិនិត្យព្យាបាលបន្ទាន់អាចធ្វើនៅថ្ងៃអាទិត្យ ថ្ងៃបុណ្យ និងពេលយប់។ ថ្លៃពិនិត្យព្យាបាលខ្ពស់ជាង។

ជំងឺ គ្រូពេទ្យ

## សៀវភៅកត់ត្រាថ្នាំពេទ្យ

អ្នកអាចទទួលបាននៅឱសថស្ថាន។ ឥតគិតថ្លៃ។
វាកត់ត្រាប្រវត្តិថ្នាំរបស់អ្នក រួមទាំងថាតើអ្នកមានអាលែកហ្ស៊ីថ្នាំ និងថ្នាំដែលអ្នកបានលេបដែរឬទេ។
វាចាំបាច់នៅពេលទៅមន្ទីរពេទ្យ ឬឱសថស្ថាន។

## ប្រព័ន្ធចំណាយថ្លៃព្យាបាលខ្ពស់

នេះគឺជាប្រព័ន្ធមួយដែលប្រសិនថ្លៃព្យាបាលដែលអ្នកបានចំណាយដោយបន្ទុកផ្ទាល់ខ្លួនក្នុងមួយខែ លើសពីចំនួនជាក់លាក់ណាមួយ នោះចំនួនលើសនឹងត្រូវប្រគល់ជូនអ្នកវិញ។
ទឹកប្រាក់អតិបរមា ខុសគ្នាទៅតាមអាយុ និងប្រាក់ចំណូលប្រចាំឆ្នាំ។
ចាំបាច់ដាក់ពាក្យសុំ។ អាសយដ្ឋានដាក់ពាក្យសុំ មានសរសេរលើប័ណ្ណធានារ៉ាប់រងសុខភាពរបស់អ្នក។

# ការចិញ្ចឹមកូន

**ប្រសិនបើមានលទ្ធភាពនៃការមានផ្ទៃពោះ ដំបូងត្រូវទៅ"មន្ទីរពេទ្យសម្ភពនិងរោគស្ត្រី"។**

ពិនិត្យមើលថាអ្នកមានផ្ទៃពោះឬអត់។
អ្នកក៏អាចប្រឹក្សាពិគ្រោះផងដែរ ប្រសិនបើមានការព្រួយបារម្ភ ឬមិនស្រួលចិត្ត ទាក់ទងនឹងការមានផ្ទៃពោះ និងការសម្រាលកូន។

**ដាក់សេចក្តីជូនដំណឹងអំពីការមានផ្ទៃពោះរបស់អ្នកទៅភូមិសង្កាត់ក្រុង។**

ទទួលបានសៀវភៅណែនាំសុខភាពមាតានិងទារក(មិនគិតថ្លៃ)។ សម្រាប់កត់ត្រាព័ត៌មានអំពីការមានផ្ទៃពោះ >ការសម្រាលកូន >សុខភាពកុមារ និងការចាក់វ៉ាក់សាំង។ ចាំបាច់ពេលពិនិត្យសុខភាពរបស់ស្ត្រីមានផ្ទៃពោះ និងការសម្រាលកូន។

ទទួលបានប័ណ្ណពិនិត្យសុខភាពមុនពេលសម្រាល ដែលមានការឧបត្ថម្ភពីមូលនិធិសាធារណៈ។
* ប្រសិនបើអ្នកផ្លាស់ទៅភូមិសង្កាត់ក្រុងផ្សេង អ្នកនឹងត្រូវផ្លាស់ប្តូរប័ណ្ណពិនិត្យសុខភាពមុនពេលសម្រាលរបស់អ្នកពីសង្កាត់ថ្មី។
* ប័ណ្ណមួយចំនួនមានភ្ជាប់មកជាមួយប័ណ្ណពិនិត្យសុខភាពធ្មេញសម្រាប់ស្ត្រីមានផ្ទៃពោះ។

**ការមានផ្ទៃពោះនិងការសម្រាលកូនរបស់អ្នកធ្វើការ**
**(ធានារ៉ាប់រងសុខភាពរបស់ក្រុមហ៊ុន និងប្រាក់សោធននិវត្តន៍សុខុមាលភាព)**

ប្រសិនបើអ្នកដឹងថាអ្នកមានផ្ទៃពោះ សូមប្រឹក្សាពិគ្រោះជាមួយក្រុមហ៊ុនរបស់អ្នកឱ្យបានឆាប់។
ច្បាប់ជប៉ុនហាមមិនឱ្យក្រុមហ៊ុនបញ្ឈប់បុគ្គលិកដោយសារការមានផ្ទៃពោះ ឬសម្រាលកូន។
សូមប្រឹក្សាពិគ្រោះជាមួយក្រុមហ៊ុនរបស់អ្នកអំពីពេលវេលាសម្រាប់ការពិនិត្យសុខភាពមុនពេលសម្រាល។ ការមានប្រាក់ឈ្នួលឬគ្មានប្រាក់ឈ្នួលគឺទៅតាម

ក្រុមហ៊ុន។
អំឡុងពេលមានផ្ទៃពោះ អ្នកអាចស្នើសុំកុំឱ្យធ្វើការបន្ថែមម៉ោង ឬធ្វើការនៅពេលយប់ជ្រៅ ឬសុំផ្លាស់ប្តូរទៅជាការងារស្រាល។
អ្នកអាចឈប់សម្រាកពីការងាររយៈពេល6សប្តាហ៍មុនថ្ងៃគ្រោងសម្រាលកូន និង8សប្តាហ៍ក្រោយសម្រាលកូន (អាស្រ័យលើលក្ខខណ្ឌ)។ ស្នើសុំទៅក្រុមហ៊ុន។
អ្នកអាចស្នើសុំការឈប់សម្រាកមើលថែកូន ពីក្រុមហ៊ុន រហូតដល់កូនរបស់អ្នកមានអាយុ1ឆ្នាំ6ខែ។

## ពេលកូនកើត



ទទួលបាន"សំបុត្រកំណើត"នៅមន្ទីរពេទ្យសម្ភពនិងរោគស្ត្រី។
សូមដាក់សំបុត្រកំណើតទៅភូមិសង្កាត់ក្រុងក្នុងរយៈពេល14ថ្ងៃ។
ឈ្មោះរបស់កូននឹងត្រូវបានសរសេរនៅលើសំបុត្រកំណើត ដូចនេះសូមជ្រើសរើសឈ្មោះត្រឹមថ្ងៃនេះ។
វាជាការល្អក្នុងការទទួលបាន "សំបុត្រទទួលចុះបញ្ជីកំណើត" និង "ប័ណ្ណស្នាក់នៅរបស់កុមារដែលមានម៉ាយណាំប័រ" នៅពេលអ្នកដាក់ពាក្យជូនដំណឹងកំណើត។ (គិតថ្លៃ)
សូមចុះឈ្មោះកូនរបស់អ្នកក្នុងធានារ៉ាប់រងសុខភាព។

ដោយមិនគិតពីសញ្ជាតិរបស់ឪពុកម្តាយ ប្រសិនបើកុមារកើតនៅប្រទេសជប៉ុន ចាំបាច់ជូនដំណឹងខាងលើ។
ប្រសិនបើឪពុកម្តាយទាំងពីរជាជនបរទេស ក៏ត្រូវជូនដំណឹងទៅស្ថានទូតក្នុងប្រទេសជប៉ុន និងអានយកដ្ឋានអន្តោប្រវេសន៍ផងដែរ។

## ការពិនិត្យសុខភាពទៀងទាត់



អាចទទួលបានការពិនិត្យសុខភាពដោយមិនគិតថ្លៃ ដើម្បីពិនិត្យសុខភាពនៅពេលកុមារអាយុ1ខែ, 3ទៅ4ខែ, 6ទៅ7ខែ, 9ទៅ10ខែ, 1ឆ្នាំ6ខែ និង3ឆ្នាំ។
អ្នកក៏អាចវាស់កម្ពស់និងទម្ងន់ ក៏ដូចជាទទួលការពិនិត្យសុខភាព និងការប្រឹក្សាពិគ្រោះជាមួយវេជ្ជបណ្ឌិតផងដែរ។
ក៏មានសេវាដែលគិលានុបដ្ឋាយិកាសាធារណៈទៅពិនិត្យដល់ផ្ទះផងដែរ ទៅតាមភូមិសង្កាត់ក្រុង។

## ការចាក់វ៉ាក់សាំង

ការចាក់វ៉ាក់សាំងចាប់ផ្តើមនៅអាយុ2ខែដើម្បីបង្កើតភាពស៊ាំ។ សូមគ្រប់គ្រង

កាលវិភាគចាក់វ៉ាក់សាំង ដោយប្រើសៀវភៅណែនាំសុខភាពមាតានិងទារក។ ទោះបីមានចំណាយមួយផ្នែកជាបន្ទុកផ្ទាល់ខ្លួន ប៉ុន្តែការចាក់វ៉ាក់សាំងទៀងទាត់ គឺមិនគិតថ្លៃទេ (មូលនិធិសាធារណៈ)។

ប្រសិនបើអ្នកមានការព្រួយបារម្ភអំពីការចិញ្ចឹមកូន អ្នកអាចប្រឹក្សាពិគ្រោះជាមួយការិយាល័យសុខភាពមាតានិងទារកក្នុងភូមិសង្កាត់ក្រុងរបស់អ្នក។

## មានប្រាក់ឧបត្ថម្ភសម្រាប់អ្នកដែលចិញ្ចឹមកូន

ប្រាក់កញ្ចប់នៃការសម្រាលកូននិងថៃទាំកុមារ៖ ប្រហែល50ម៉ឺនយ៉េនក្នុងកូន1នាក់ សម្រាប់អ្នកដែលបានសម្រាលកូនបន្ទាប់ពីមានផ្ទៃពោះចាប់ពី4ខែ
ប្រាក់ឧបត្ថម្ភកូន៖ សម្រាប់អ្នកដែលចិញ្ចឹមកូនរហូតដល់អាយុ15ឆ្នាំ។

មួយណាក៏ចាំបាច់មានពាក្យសុំ។

## ការគាំទ្រដល់ឪពុកម្តាយតែម្នាក់

ប្រាក់ឧបត្ថម្ភការចិញ្ចឹមកូន៖ សម្រាប់ឪពុកម្តាយដែលចិញ្ចឹមកូនរហូតដល់អាយុ18ឆ្នាំ។
ប្រាក់កម្ចីសុខុមាលភាពដល់ម្តាយកូន ឪពុកកូន ឬស្ត្រីមេម៉ាយ៖ គឺជាប្រព័ន្ធប្រាក់កម្ចីដើម្បីគាំទ្រឯករាជ្យភាពផ្នែកសេដ្ឋកិច្ច។
ប្រាក់ឧបត្ថម្ភថ្លៃព្យាបាលសម្រាប់គ្រួសារដែលមានឪពុកម្តាយតែម្នាក់៖ គឺជាប្រព័ន្ធឧបត្ថម្ភថ្លៃព្យាបាល។

**ចង់ដឹងបន្ថែម**
ច្រកការិយាល័យ"អប់រំនិងសុខភាព" នៃភូមិសង្កាត់ក្រុង
សមាគមធានារ៉ាប់រងសុខភាពជាតិ

**ទូរស័ព្ទប្រឹក្សាពិគ្រោះកង្វល់គ្រួសារ**
មជ្ឈមណ្ឌលប្រឹក្សាស្ត្រីខេត្តគីម៉ាម៉ុតុ (សេវាប្រឹក្សាស្ត្រី) 096-381-4454
មជ្ឈមណ្ឌលប្រឹក្សាស្ត្រីខេត្តគីម៉ាម៉ុតុ (ប្រឹក្សាហិង្សាក្នុងគ្រួសារ) 096-381-7110
ការប្រឹក្សាពិគ្រោះតាមទូរស័ព្ទអំពីការមានផ្ទៃពោះ នឹងសុខភាពផ្លូវចិត្ត (កង្វល់របស់ស្ត្រីទាក់ទងនឹងការមានផ្ទៃពោះ ការសម្រាលកូន និងផ្លូវភេទអំឡុងពេលវ័យជំទង់) 096-381-4340
កង្វល់ដែលទាក់ទងនឹងកុមារ ដូចជាការអភិវឌ្ឍរបស់កុមារ វិន័យ ការប្រឹក្សាថៃទាំកុមារ (រួមទាំងការរំលោភបំពាន) ពិរុទ្ធភាពនៃអនីតជន ការបដិសេធមិនចូលសាលាជាដើម។
ការិយាល័យកណ្តាលប្រឹក្សាកុមារ ខេត្តគីម៉ាម៉ុតុ 096-381-4451

# ការអប់រំកុមារ

## មណ្ឌលមើលថែ / ទារកដ្ឋាន

ទទួលមើលថែកុមារចាប់ពីអាយុ0ឆ្នាំរហូតដល់ពួកគេចូលរៀននៅសាលាបឋមសិក្សា ខណៈដែលឪពុកម្តាយរបស់ពួកគេកំពុងធ្វើការ។ ចំពោះការដាក់ពាក្យសុំចូលរៀន សូមប្រឹក្សាពិគ្រោះជាមួយផ្នែកទារកដ្ឋាន នៃភូមិសង្កាត់ខណ្ឌក្រុងរបស់អ្នក

## ទារកដ្ឋានដែលមានការបញ្ជាក់

ទទួលមើលថែកូនចាប់ពីអាយុ0ឆ្នាំរហូតដល់ពួកគេចូលរៀននៅបឋមសិក្សា មិនថាឪពុកម្តាយធ្វើការឬអត់នោះទេ។

## ទារកដ្ឋាន

ជាសាលាសិក្សាសម្រាប់កុមារចាប់ពីអាយុ3ឆ្នាំដល់ចូលបឋមសិក្សា។

# ការអប់រំនៅសាលា

នៅប្រទេសជប៉ុន ឪពុកម្តាយមានកាតព្វកិច្ចឱ្យកូនទទួលបានការអប់រំពី6ទៅ15ឆ្នាំ។




* មាន"សាលាជំនួយពិសេស"ដែលគាំទ្រឯករាជ្យភាពរបស់កុមារពិការ។

ប្រសិនបើអ្នកចង់ចុះឈ្មោះកូនចូលរៀននៅសាលាមត្តេយ្យសាធារណៈ ទារកដ្ឋាន សូមប្រឹក្សាពិគ្រោះជាមួយច្រកនិមួយៗនៃភូមិសង្កាត់ក្រុង។
សម្រាប់ការចូលរៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យ សូមប្រឹក្សាពិគ្រោះជាមួយក្រុមប្រឹក្សាអប់រំតាមភូមិសង្កាត់ក្រុង។
សម្រាប់ការចូលរៀននៅសាលារដ្ឋ ឬឯកជន សូមទាក់ទងសាលាដោយផ្ទាល់។
សម្រាប់ការចូលរៀននៅវិទ្យាល័យ ចាំបាច់ប្រឡងជាប់។

ក៏មានកន្លែងផ្តល់ការបង្រៀនភាសាជប៉ុនសម្រាប់កុមារដែលមិនអាចនិយាយភាសាជប៉ុនបានល្អផងដែរ។

សូមប្រឹក្សាពិគ្រោះជាមុនជាមួយក្រុមប្រឹក្សាអប់រំនៃភូមិសង្កាត់ក្រុង។

## សាលាអន្តរជាតិ

ជាកន្លែងអប់រំសម្រាប់កុមារដែលមានសញ្ជាតិបរទេស។
ភាសានិងកម្មវិធីសិក្សាដែលប្រើក្នុងសាលារៀនខុសគ្នាអាស្រ័យលើសាលា។
សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងសាលាដោយផ្ទាល់។

## សាលាពេលយប់

ជាសាលាដែលមានថ្នាក់រៀនពេលយប់។
ជនបរទេសដែលមិនទាន់បានបញ្ចប់ការសិក្សានៅអនុវិទ្យាល័យជប៉ុនក៏អាចចូលរៀនបានដែរ។
បន្ទាប់ពីបញ្ចប់ការសិក្សា ពួកគេអាចប្រលងចូលវិទ្យាល័យបាន។
សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងផ្នែកអប់រំកាតព្វកិច្ចខេត្តគីម៉ាម៉ុតុ (096-333-2689) ។

ការអប់រំកុមារ

# ត្រៀមសម្រាប់គ្រោះមហន្តរាយ

## ខិត្តប័ណ្ណស្តីពីការការពារគ្រោះមហន្តរាយសម្រាប់ជនបរទេស

https://www.pref.kumamoto.jp/soshiki/4/5195.html

## រញ្ជួយដី



ការរញ្ជួយដីអាចកើតឡើងភ្លាមៗ ដូច្នេះវាមានសារៈសំខាន់ណាស់ក្នុងការត្រៀមប្រចាំថ្ងៃ។

- ដាក់ឱ្យជាប់នូវគ្រឿងសង្ហារឹម។
- ទទួលការពិនិត្យភាពធន់នឹងការរញ្ជួយដី និងធ្វើការពង្រឹងចាំបាច់នៃផ្ទះ។
- ពិនិត្យទីតាំងនៃសាលាបឋមសិក្សា និងមជ្ឈមណ្ឌលសហគមន៍ (កន្លែងជម្លៀសសង្គ្រោះបន្ទាន់ដែលបានកំណត់) កន្លែងសុវត្ថិភាព ដូចជាផ្ទះរបស់សាច់ញាតិ និងអ្នកស្គាល់គ្នា សណ្ឋាគារ និងផ្លូវជម្លៀស ដែលនៅក្បែរ។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការការពារគ្រោះមហន្តរាយ។









## ប្រសិនកើតមានរញ្ជួយដី

### ពេលនៅក្នុងផ្ទះឬអាគារ

- ប្រសិនបើអ្នកមានអារម្មណ៍ញ័រ សូមលាក់ខ្លួននៅក្រោមតុជាដើម។
- កុំស្ទុះប្រញាប់ហក់ទៅខាងក្រៅរហូតដល់ការញ័រថយចុះ។
- នៅពេលការញ័របានថយចុះហើយ ដំបូងសូមពន្លត់អគ្គីភ័យ។
- ពាក់ស្បែកជើងស្លីពព័រ ឬស្បែកជើងធម្មតានៅពេលផ្លាស់ទី ដើម្បីជៀសវាងការរងរបួសដោយការជាន់កញ្ចក់ដែលបែកជាដើម។



## ពេលនៅក្រៅផ្ទះឬអាគារ

- ការពារក្បាលរបស់អ្នកជាមួយនឹងកាបូប ឬអីវ៉ាន់ក្នុងដៃ ហើយជម្លៀសទៅកាន់កន្លែងដែលមានសុវត្ថិភាព ដូចជាសួនសាធារណៈ ឬកន្លែងទំនេរ ដែលមិនមានគ្រោះថ្នាក់នៃការធ្លាក់របស់របរ។

## ពេលជិះរថភ្លើងឬឡានក្រុង

- ពេលអង្គុយលើកៅអី, ការពារក្បាល និងរក្សាជំហរបស់អ្នកឱ្យទាប ។
- ពេលឈរ, កាន់ខ្សែតោង ឬដៃកាន់ដើម្បីកុំឲ្យដួល។

នៅពេលកើតមានរញ្ជួយដី, រាងកាយរបស់អ្នករឹង ហើយចិត្តរបស់អ្នកស្លុង ដែលធ្វើឱ្យពិបាកក្នុងការសម្រេចចិត្តត្រឹមត្រូវ។ វាសំខាន់ក្នុងការប្រមើលមើលថាតើអ្នកគួរធ្វើសកម្មភាពបែបណា។

## ការពារជីវិតរបស់អ្នកជាអាទិភាពចម្បង

- ខណៈពេលកំពុងសង្កេតមើលសភាពជុំវិញខ្លួនអ្នក ត្រូវប្រាកដថាធ្វើសកម្មភាពសុវត្ថិភាពទាំងបី (រក្សាខ្លួនឱ្យទាប ការពារក្បាលរបស់អ្នក និងកុំផ្លាស់ទី) ហើយធ្វើសកម្មភាពជាអាទិភាពចម្បងរបស់អ្នកក្នុងការការពារអាយុជីវិត និងគ្រួសាររបស់អ្នក។

## ខ្យល់ព្យុះ

នៅខេត្តគីម៉ាម៉ុតុ កំពុងកើតមានការខូចខាតដោយសារព្យុះទីហ្វុង និងភ្លៀងធ្លាក់ខ្លាំង។ អ្នកអាចទស្សន៍ទាយស្ថានភាពជាមុន ដូច្នេះសូមប្រមូលព័ត៌មាន និងជម្លៀសខ្លួនឱ្យបានឆាប់។

## ការប្រមូលព័ត៌មានអំពីគ្រោះមហន្តរាយ

- ព័ត៌មានព្រមានអំពីការរលំបាក់ដី និងព័ត៌មានហានិភ័យទឹកជំនន់ដែលប្រកាសដោយទីសង្កេតការណ៍ឧតុនិយម
- ព័ត៌មានអំពីការជម្លៀសចេញដោយភូមិសង្កាត់ក្រុង

## ការបញ្ជាក់អំពីកន្លែងគ្រោះថ្នាក់ និងផ្លូវជម្លៀសក្នុងតំបន់

- ត្រូវក្តាប់ និងបញ្ជាក់ផ្លូវជម្លៀសជាមុនដោយប្រើផែនទីគ្រោះថ្នាក់ (ផែនទីការពារគ្រោះមហន្តរាយ) ដែលបង្កើតដោយភូមិសង្កាត់ក្រុង។

## ពេលភ្លៀងទំនងនឹងធ្លាក់ខ្លាំង, ត្រូវមានវិធានការជម្លៀសខ្លួនឱ្យបានឆាប់!

- ក្នុងករណីភ្លៀងធ្លាក់ខ្លាំងត្រូវបានព្យាករណ៍ ត្រូវគិតមានវិធានការជម្លៀស ពេលថ្ងៃភ្លឺ មុនភ្លៀងចាប់ផ្ដើមធ្លាក់ខ្លាំង!

- បង្កើត "ម៉ាយថាមឡាញ (ផែនការសកម្មភាពពេលគ្រោះមហន្តរាយផ្ទាល់ខ្លួន)" ដែលសង្ខេបអំពីពេលវេលានៃការចាប់ផ្ដើមការជម្លៀស និងសកម្មភាពជម្លៀស ទៅតាមកម្រិតប្រកាសអាសន្ន។

## សកម្មភាពពេលគ្រោះមហន្តរាយ

ចំណុចប្រុងប្រយ័ត្នពេលជម្លៀស

- បិទភ្លើងដូចជាចង្ក្រាន និងកន្លែងឧស្ម័ន
- បិទប៉ាវែតអគ្គិសនី
- បិទសន្ទះប្រភពឧស្ម័ន
- នៅពេលជម្លៀសចេញ សូមទុកក្រដាសបិតជាសញ្ញាដែលមានព័ត៌មានអំពីសុវត្ថិភាពរបស់អ្នក និងក្រុមគ្រួសាររបស់អ្នក ហើយចាក់សោផ្ទះមុនពេលផ្លាស់ទី។
- សូមគិតដល់ថាប្រព័ន្ធទូរសព្ទអាចដាច់ ហើយទាក់ទងតាមលេខសារគ្រោះមហន្តរាយឬSNS។

















## ទីកន្លែងជម្លៀស

ជាកន្លែងទទួលជនរងគ្រោះដោយគ្រោះមហន្តរាយជាបណ្ដោះអាសន្ន ដែលមិនមានលទ្ធភាពរស់នៅក្នុងផ្ទះរបស់ពួកគេនៅពេលកើតមានគ្រោះមហន្តរាយ។ ការផ្គត់ផ្គង់ជំនួយសង្គ្រោះនឹងត្រូវបញ្ជូនទៅទីកន្លែងជម្លៀសដែលកំណត់ដោយភូមិសង្កាត់ក្រុងផងដែរ។
ព័ត៌មាន"បើកXXជាទីកន្លែងជម្លៀស" ត្រូវបានផ្ដល់ពីភូមិសង្កាត់ក្រុង នៅលើSNS, វិបផេក, ទូរទស្សន៍ និងវិទ្យុ។
ប្រសិនបើអ្នកមានអារម្មណ៍ថាផ្ទះរបស់អ្នកស្ថិតក្នុងគ្រោះថ្នាក់ អាចនឹងត្រូវខូចខាត សូមទៅកាន់ទីកន្លែងជម្លៀសដែលនៅជិតបំផុតឱ្យបានឆាប់។
អ្នកអាចជម្លៀសមិនត្រឹមតែទៅកាន់ទីកន្លែងជម្លៀសប៉ុណ្ណោះទេ ថែមទាំងអាចទៅផ្ទះសាច់ញាតិ ឬអ្នកស្គាល់គ្នា ឬទៅអគារក្រុមហ៊ុន ដរាបណាវាមានសុវត្ថិភាព។

ព័ត៌មានក៏ត្រូវបានផ្ដល់ផងដែរនៅទីកន្លែងជម្លៀសដែលកំណត់ដោយភូមិសង្កាត់ក្រុង។
ប្រសិនបើមាននរណាម្នាក់ដែលមិនអាចទាក់ទងបាន សូមសួរ។

# ពេលអាសន្ន

## គ្រោះថ្នាក់

អគ្គីភ័យ របួស ជំងឺភ្លាមៗ គ្រោះថ្នាក់ចរាចរណ៍ (ពេលមានអ្នករងរបួស)
ចុចលេខ119 នៅលើទូរសព្ទ។
① ប្រាប់ថាតើវាជាអគ្គីភ័យ ឬជាសង្គ្រោះបន្ទាន់។
② តើជាស្ថានភាពបែបណា (សន្លប់ របួស។ល។)
③ ប្រាប់ពីអាសយដ្ឋាន និងព័ត៌មានទំនាក់ទំនង (អគារសម្គាល់ក្បែរនោះ ។ល។)

## ប៉ូលីស

ចុចលេខ110 នៅលើទូរសព្ទ។
ពេលមានដូចខាងក្រោម ហើយចង់ឲ្យប៉ូលិសមកភ្លាម
ពេលមានអំពើចោរកម្ម លួច ឬឆក់
ពេលឃើញគ្រោះថ្នាក់ចរាចរណ៍
នៅពេលដែលផ្លូវត្រូវបានបិទដោយការរលំបាក់ដី

① ប្រាប់ពីស្ថានភាព ថាតើវាជាឧបទ្ទវហេតុ ឬគ្រោះថ្នាក់។
② ពេលណាកើតមាន
③ ប្រាប់ពីអាសយដ្ឋាន និងព័ត៌មានទំនាក់ទំនង (អគារសម្គាល់ក្បែរនោះ ។ល។)

# ប្រឹក្សាពិគ្រោះ

មជ្ឈមណ្ឌលគាំទ្រជនបរទេសខេត្តគឹម៉ាម៉ុតុ

080-4275-4489

@KumamotoSupportCenterforForeignResidents

編集・発行　熊本県国際協会